ឧបសៅសង្ហា

# ឈ្នះនៅឆ្នាំ២០១៨ខុសនឹងឈ្នះឆ្នាំ ២០១៣បែបណា ?



## មាតិការឿង


នរណាជាអ្នកចាញ់ ........ 2
នរណាជាអ្នកឈ្នះ ........ 3
មួយជំហានម្ដងៗ ........ 4
សេចក្ដីសន្និដ្ឋាន ........ 7


២៣ តុលា ២០១៥

# គំនិតចាក់ស្មុគ្រ ?

## នរណាជាអ្នកចាញ់

គឺ គណបក្ស ប្រជាជនកម្ពុជា ព្រោះគណបក្សនេះ មិនដែលឈ្នះឆ្នោតម្តងណាឡើយ តាមផ្លូវច្បាប់ តាំងពី ឆ្នាំ ១៩៩៣ មកម្លេះ។ ដូច្នេះ មិន ពិបាកប៉ាន់ អ្វី នោះឡើយ ថា នរណាជាអ្នកចាញ់។ ខ្មែរ ឮ សំដី លោក ហ៊ុន សែន ស្រាប់ហើយ ថា បើ គណបក្ស ប្រជាជន ចាញ់ នឹងមាន សង្គ្រាម។ លោក ហ៊ុន សែន និយាយក្នុង ទម្រង់ ជា ការចង្អុលអោយ ដំណឹង ថាជាការពិត (mode indicatif)។ តែសំដីនេះ វា មិនមែន ជា សេចក្តីពិតដាច់ខាត (vrai relatif) ព្រោះ ការបោះឆ្នោត តាម លទ្ធិប្រជាធិបតេយ្យ វា មិនមែន ជា ការប្រកួត អាវុធ រវាង យុទ្ធការី។ បើ លោក ហ៊ុន សែន គាត់ មាន ជំនឿបែបនេះហេតុអ្វីក៏គាត់ ចូលរួមបោះឆ្នោតធ្វើអ្វី ? សំដីបែបនេះ គេអាចទុកគាត់ជា ភណ្ឌនការី (អ្នកបង្កជម្លោះ)។ តែ លោជា មានសង្គ្រាមកើតពិតមែន ដូច លោក ហ៊ុន សែន និយាយ សង្គ្រាមនេះ គ្មានរូបរៀង ជាសង្គ្រាមនោះទេ ព្រោះ វា គ្មាន យុទ្ធការី ប្រឆាំងនឹង ការបោះឆ្នោតនោះឡើយ។ សង្គ្រាម ដែលមាន នៅក្នុងគំនិត លោក ហ៊ុន សែន គឺពិតជា រដ្ឋប្រហារ ធ្វើឡើង ដោយ កងកម្លាំង ការពារ លោក ហ៊ុន សែន តែប៉ុណ្ណោះ។ ដូចថ្មីៗនេះ លោក ហ៊ុន សែន ប្រគល់អំណាចឃោជារមួយភាគ ឲកូនប្រុសទី២ របស់គាត់ ទង្វើនេះ ជា ការគំរាម កំហែង ដល់ ប្រជាពលរដ្ឋខ្មែរ ថា បើចង់ដូរគាត់ គឺមានសង្គ្រាមនោះឯង ហើយ គាត់ មិន និយាយ លេង នោះទេ។ លោក ហ៊ុន សែន អាចនឹងធ្វើ រដ្ឋប្រហារបាន តែមិនពិតថា គាត់ អាច ទាញ ផល ពី វា បានទេ ព្រោះ រដ្ឋប្រហារ របស់គាត់ វា គ្មានការគាំពារ ពីសំណាក់ សហគមន៍អន្តរជាតិនោះឡើយ ហើយ មិនពិត ជាមិត្ត ចិន/យួន របស់គាត់ ប្រកាសគាំទ្រ ដោយចេញមុខនោះដែរ។ រដ្ឋប្រហារនេះ ជា ទង្វើ ផ្សងព្រេងតែប៉ុណ្ណោះ។ ហ៊ុន សែន អាចរក្សាអំណាចបាន តាមការធ្វើ រដ្ឋប្រហារ តែនៅក្នុងតម្លៃ មួយ ថ្លៃណាស់ សំរាប់គាត់ ដូច្នេះ គាត់មានតែខាត តែប៉ុណ្ណោះ។ ហេតុនេះ គាត់នឹងវិលត្រឡប់ មក ប្រើវិធីចាស់ របស់គាត់ គឺទិញដូរ អ្នកប្រឆាំងនឹងគាត់ ដែល ខ្មែរ យើងធ្លាប់ឃើញ រួចហើយ ថា គណបក្ស ប្រជាជន តែងតែ ក្លែង ការចាញ់ឆ្នោត របស់គេឲក្លាយ ជាជ័យជំនះ តាម មធ្យោបាយ ក្រៅច្បាប់ជានិច្ច គឺ ដូរដោះ យសស័ក្កិ ជាមួយ គណបក្ស ឈ្នះឆ្នោត ឲសុខចិត្ត បោះបង់ ជ័យជំនះ ដូចមាន កើតឡើង នៅ ក្នុង ឆ្នាំ ២០១៣-២០១៤ ជា ឧទាហរណ៍។ នៅ ឆ្នាំ ២០១៨ អាច នឹងមាន កើតឡើង ម្តងទៀត នៃ ការសម្រុះសម្រួលគ្នា បែបនេះ ព្រោះ ទាំងគណបក្សកាន់អំណាច និង គណបក្ស ចូលរួម បោះឆ្នោត មិនដែល ទុក ប្រជាពលរដ្ឋ ជា ម្ចាស់ឆ្នោត នោះឡើយ គេ គ្រាន់តែ ទុក ជា អ្នកបោះឆ្នោត តែប៉ុណ្ណោះ ព្រោះ ក្រោយ ពី ការបោះឆ្នោត ម្តងៗ ពួកគេ តែងតែទុកខ្លួនគេ ជាម្ចាស់នៃលទ្ធផល នៃ ការបោះឆ្នោត ហើយ គេ នាំ គ្នា ចែកតួនាទី គ្នា ថា អ្នកណា ជា អ្នកឈ្នះ អ្នកណា ជា ចាញ់ ក្នុង ប្រយោជន៍ របស់គេ រៀងៗខ្លួ

ន។ តើខ្មែរយើង អាចចាត់ទុក ការបោះឆ្នោតបែបនេះ ជា នីតិវិធី មជ្ឈិត បានដែរ ឬទេ ? បើខ្មែរយើងនៅតែយល់ឃើញថា វាជា ផ្លូវ គ្មាន ជម្រើស របស់ខ្លួន។ កិច្ច (acte) នេះ ជា សទ្ធិរបស់ ពលរដ្ឋខ្មែរ ដែលគ្មាននរណា អាច ទិញដូរ បាន នោះឡើយ តែ ផ្លូវ នេះ ជា ផ្លូវទាល់ តែ ប៉ុណ្ណោះ។ តែបើខ្លួនទុក ខ្លួន ជា ម្ចាស់ អំណាច គឺ មិន ត្រូវទទួលស្គាល់ ជា ដាច់ខាត នូវ គ្រប់ ការសម្រុះសម្រួលណា ដែល ខុស ពីឆន្ទៈ របស់ខ្លួន និង គ្មានមូលដ្ឋានច្បាប់សំរាប់ជានា។ បើ មាន ការសម្រេចចិត្ត បែបនេះ ទើបគេអាចទុក ម្ចាស់ឆ្នោត ដែលជា ពលរដ្ឋ មាន ការទទួលខុសត្រូវ ចំពោះកិច្ច របស់ខ្លួន។ ពុំនោះ កុំនាំគ្នាចោទ ប្រកាន់ អ្នក នយោបាយ ថា ជា អ្នកបោកប្រាស់ ព្រោះ ខ្លួនទេ ដែលទុក ឲ គេបោកប្រាស់ ហើយនាំគ្នារស់ជាសោកី (មនុស្សមានទុក្ខ) ក្នុងភាពក្រលំបាក រហូតដល់ថ្ងៃស្លាប់។

## នរណាជាអ្នកឈ្នះ

បើ ការបោះ ឆ្នោត ២០១៨ មាន តម្លាភាពពិត អ្នកឈ្នះ គឺ គណបក្ស ជាភាគីប្រឆាំង នឹង គណបក្ស កាន់អំណាច។ នៅ ពេលបោះឆ្នោត ក្នុង ឆ្នាំ ២០១៣ អ្នកឈ្នះ គឺ គណបក្ស សង្គ្រោះជាតិ។ ជ័យជំនះនេះ បញ្ជាក់បន្ថែម តាម មហាបាតុកម្ម នៃ មហាជន ទាមទារ ឲ គោរពឆន្ទៈ របស់ខ្លួន ដែលជាម្ចាស់ឆ្នោត ព្រោះអ្នកចាញ់ បានប្រកាស ដោយបំពានច្បាប់ ថាខ្លួនជាអ្នកឈ្នះ។ មួយ ឆ្នាំ ក្រោយមក គណបក្ស ឈ្នះឆ្នោតទទួលស្គាល់លទ្ធផល ផ្ទុយ ពី ឆន្ទៈម្ចាស់ឆ្នោត រំលោភច្បាប់ នាំគ្នាដើរ សស្រោក ចូល រដ្ឋសភា ក្នុងកិច្ចព្រមព្រៀង បែងចែក កៅអី ដោយ សុខចិត្ត ទទួលសម្លេង របស់តំណាង គណបក្សប្រជាជន បោះឆ្នោតឲ ខ្លួន អង្គុយ លើ កៅអី តំណែង ដែល បានមកពី ការប្លន់ពីម្ចាស់ឆ្នោត ហើយ យកមកចែក គ្នា ទាំងថ្ងៃ នៅ ចំពោះ មុខ មហាជន។ សួរថា តើ ទង្វើនេះ ជា សីលគន្ធ (bonne conduite) ដែរឬទេ ?

សួរបន្ថែមទៀតថា តើ អ្នកឈ្នះឆ្នោត នៅ ឆ្នាំ ២០១៨ សុខចិត្ត ដាក់ ខ្លួន ជា អ្នកចាញ់ឆ្នោត ហើយ នាំគ្នា ដើរ ចូល រដ្ឋសភា ដូច នៅ ឆ្នាំ ២០១៤ ដែរ ឬអី ? បើយោងតាមច្បាប់ បោះឆ្នោតថ្មី បញ្ហា នៃ សុពលភាព នៃ រដ្ឋសភា កើតមានពី ពហិការ ពីសំណាក់ គណបក្ស វិវាទករ លើលទ្ធផល នៃ ការបោះឆ្នោត មិនចូល ប្រជុំបើ អង្គនីតិបញ្ញត្តិថ្មី តាម ការកោះអញ្ជើញ ពី ព្រះមហាក្សត្រ លែងមានហើយ ព្រោះ បើ គណបក្សណាមិនចូល ប្រជុំ ក្នុង ករណី បែបនេះ គ.ជ.ប. គេ នឹងយកអាសនៈ ខ្លួន ទៅ ចែកបន្ថែម ឲ គណបក្ស ណា ដែល មានអាសនៈ ហើយ ចូលប្រជុំ។ ដូច្នេះ បើ គ.ជ.ប. គេប្រកាស ថា គណបក្សណាមួយ ជាអ្នកឈ្នះ ហើយ ទី ព្រឹក្សារដ្ឋធម្មនុញ្ញ គេទទួលស្គាល់នូវ ជ័យជំនះនេះ ទោះបី ជា ជ័យជំនះ ក្លែងបន្លំ ក្តី ដូចកាល ពី ឆ្នាំ២០១៣ តើ គណបក្ស ឈ្នះឆ្នោតពិត ត្រូវ ប្រកាន់យក អាកប្បកិរិយា បែបណា នៅចំពោះ អំពើ អ

យុត្តិធម៌ ដដែលនេះ ? តែ ចម្លើយនេះ វា សម្រេចនៅត្រង់ ថាតើ ម្ចាស់ឆ្នោត មាន មនោសរៈ ច្បាស់លាស់ ហ៊ាន ការពារ ឆន្ទៈ របស់ខ្លួនដែរឬទេ ? បើគ្មាននោះទេ អ្វីដែល មាន កើតឡើង នៅ ក្នុង ឆ្នាំ ២០១៣-២០១៤ នឹង មាន កើត ឡើង សារ ជា ថ្មី។ ដូច្នេះ ការបោះឆ្នោត ឆ្នាំ ២០១៨ ជាការបោះឆ្នោត គ្មានប្រយោជន៍ អ្វី ដល់ ប្រជាពលរដ្ឋខ្មែរ នោះឡើយ។ ចម្លើយនេះ ក៏ វា ស្រេច នៅ លើ សម្ថានភាព នៃ គណបក្សប្រឆាំង នោះ ដែរ ថា ខ្លួនហ៊ាន ប្រឈរមុខ ការពារ យុត្តិធម៌ ស្របតាម ការប្រកាស ថា ខ្លួន នឹង ការពារឆន្ទៈ ម្ចាស់ឆ្នោត ជា ដាច់ខាត នៅ ចំពោះមុខ អយុត្តិធម៌នេះ។ តែខ្មែរយើង ធ្លាប់ឮ ពាក្យ សន្យា របស់ គណបក្ស សង្គ្រោះជាតិ កាល ពី ឆ្នាំ ២០១៣ រួចមកហើយ ហើយច្បាស់ ជា គេ នឹង ធ្វើ ម្តងទៀត ដើម្បី ស្វែង រកសន្លឹកឆ្នោត។ សួរថា តើពាក្យ សន្យាស្មើនឹង ពាក្យសំបថ នេះ អាចក្លាយ ជា ពាក្យក្បត់ ជាថ្មី ដែរ ឬទេ ? តើប្រជា ពលរដ្ឋ នឹងអាច ជឿ ជា ថ្មី នូវ គ្រប់សំដី របស់ គណបក្ស សង្គ្រោះជាតិ បានដែរ ឬទេ ? តែ សំណួរ ដែលសំខាន់ គឺ សួរថា ពួក អ្នកឈ្នះឆ្នោត មានមធ្យោបាយ បែបណា អាច យក អំណាច បាន តាមផ្លូវច្បាប់ នៅពេល ដែល ខ្លួនឈ្នះឆ្នោត ? បើរកឃើញ មធ្យោបាយនេះ គឺ ពិត ជា អាចបញ្ចប់អំណាច របបផ្តាច់ការបាន ហើយ ច្បាស់ជាគ្មាន កើតរឿងអាស្រូវ ដូចឆ្នាំ២០១៣ នោះឡើយ។ បើ ចូលបោះឆ្នោត ត្រូវ មានចម្លើយនឹង បញ្ហានេះ បើគ្មាន គឺ ជា ការបោកប្រាស់ ម្ចាស់ឆ្នោត ជា ថ្មី ម្តងទៀតហើយ។

## មួយជំហានម្តងៗ

ចម្លើយ នេះ ច្បាស់ ជា អ្នកដឹកនាំ គណបក្ស សង្គ្រោះជាតិ គេ ឆ្លើយថា ត្រូវ មាន អំណត់ ត្រូវ យើង នាំ គ្នា ដើរ មួយជំហានម្តងៗ គឺថា បោះឆ្នោតសិន សុំគិត បន្តទៅ ទៀត។ ពួកទាំងនេះ មិនដែល គិត ទុកជាមុន រក ចម្លើយ ដោះស្រាយ បញ្ហា ដែលនឹង មានកើតឡើង តែ បែរ ជា នាំគ្នា គេច បញ្ហា ជា និច្ច ហើយ ចេះតែនាំគ្នាស្នើរ បង្កើត ច្បាប់ថ្មី ដែល វា គ្មាន ស័ក្តិសិទ្ធ អ្វីបន្តិច សោះ សំរាប់ រកការដោះស្រាយ នៃបញ្ហា ព្រោះ បញ្ហា វា មិនមែន ស្ថិតនៅត្រង់ ខ្វះច្បាប់ គឺ វានៅត្រង់ថា អ្នកនយោបាយខ្មែរ គ្រប់ និន្នាការ នយោបាយ គាត់មិននាំគ្នា គោរព ច្បាប់។ ដូច្នេះ ដំណើរ មួយជំហានម្ត ងៗ ក្រៅច្បាប់ វា ជា ដំណើរ គ្មាន សេចក្តីប្រាកដ គ្មានភាព ការពារខ្លួន ហើយដើរ ម្តង ទៅមុខ ម្តងមកក្រោយ ដែល ជា ជំហ៊ាន មិនអាច ពង្រឹង ជំហរខ្លួនបាននោះឡើយ។ នៅក្នុង ស្ថានភាពបែប នេះ គេ សន្និដ្ឋានបាន ថា គណបក្សប្រឆាំង មាន លក្ខណៈ គ្រាន់ ជា បក្ស សំអាង ឲយើញថា មានអ្នកប្រឆាំង (alibi) តែប៉ុណ្ណោះ ដើម្បី លំអ របប ផ្តាច់ការ។ ដូច្នេះគេ អាច សួរ បានថា តើ គ្រប់ គណបក្សប្រឆាំង សព្វថ្ងៃ មាន គុណ សម្បត្តិ ជា គណបក្សនយោបាយ ដែរឬទេ ?គណបក្ស នយោបាយ ភាគច្រើន ជា គណ បក្ស សំរាប់តែបោះឆ្នោត ជា បក្ស របស់បុគ្គល ឬ ក្រុម បុគ្គល មាន សកម្មភាព

នយោបាយ នៅ ពេលបោះឆ្នោត តែប៉ុណ្ណោះដែលនាំឲខូច តម្លៃ នៃ លទ្ធិប្រជាធិបតេយ្យ ហុច ចំណេញ ដល់ ពួក អ្នកផ្ដាច់ការនិយម ប្រើ លទ្ធិប្រជាធិបតេយ្យ ក្លែងក្លាយ ជាមធ្យោបាយ សំរាប់ ប្លន់យកអំណាចហើយ រក្សា វា ឲបានគង់វង់ ដើម្បី រកមធ្យោបាយ ស្វែងរក អត្ថប្រយោជន៍ ឲបក្សពួកខ្លួន។ លទ្ធិ ប្រជាធិបតេយ្យ ក្លែងក្លាយ នេះ មានឈ្មោះរបស់វា ថា លទ្ធិ ប្រជាធិបតេយ្យ ការពារ អំណាច ឬ អប្បជនាធិបតេយ្យ សម័យ (démocratie tutélaire ou oligarchie moderne) ដែល ជា របប នយោបាយ មួយ មានរូបរាង ជា លទ្ធិប្រជាធិបតេយ្យ តែមាន ធាតុអំណាច ជា អំណាច ផ្ដាច់ការ ដែល ផ្ទុយគ្នា ស្រឡះពី លទ្ធិប្រជាធិបតេយ្យ សេរី ដែល ប្រើគ្រប់ មធ្យោបាយ ជា បទដ្ឋាន សំខាន់ពីរយ៉ាង៖ ធ្វើយ៉ាងណា កុំអោយ មាន អំណាច ផ្ដាច់ការ រំលោភ បំពាន លើ ប្រជាពលរដ្ឋ និង ធ្វើ ឲ ប្រជាពលរដ្ឋ មានសេចក្ដីក្លាហាន ចូលរួម ជា សកម្ម ក្នុង កិច្ចការនយោបាយជាតិ។ ឧទាហរណ៍៖ របបនយោបាយ នៅ ស្រុកខ្មែរ បច្ចុប្បន្ន ជា របប លទ្ធិប្រជាធិបតេយ្យ ក្លែងក្លាយ ដូចរៀបរាប់ខាងលើនេះ ព្រោះ មាន អំណាចផ្ដាច់ការ ប្រើអំណាច ចាប់ អ្នកប្រឆាំងខ្លួនដាក់គុក និង គំរាម ជានិច្ច ដល់ ប្រជាពលរដ្ឋ ថា បើមាន ការប្តូរ អ្នកដឹកនាំ គឺមានកើតសង្គ្រាមស៊ីវិល។

គណបក្ស សង្គ្រោះជាតិ បច្ចុប្បន្ន គឺ ថិតនៅ លើខ្សែខណ្ឌ រវាង គុណសម្បត្តិ ជា គណបក្សនយោបាយ ពិតប្រាកដ និង គណបក្ស នយោបាយ សំរាប់ បោះឆ្នោត។ ជួនកាលជ្រុល ចូល ទៅខាងនេះម្ដង ខាងនោះម្ដង ទៅតាម អាបោធាតុ (អារម្មណ៍) របស់អ្នកដឹកនាំខ្លួន ដែល មាន ឋានៈ ស្ទើរ តែ ជាម្ចាស់ នៃគណបក្ស និង មាន ធាតុកំណើតគណបក្ស ជា សមាគមនយោបាយសម្ងាត់ (hétérie) រវាង អ្នកដឹកនាំ ដូចជា គណបក្សសមរង្ស៊ី និង សិទ្ធិមនុស្ស មានការសម្ងាត់ ដែលគ្មាននរណា ដឹងច្បាស់ថា ពួកគេចង់បានអ្វីពិតប្រាកដ ក្រៅតែមាន ពាក្យស្លោក ថា «ដូរ ឬ មិនដូរ ?» នៅ ក្នុង ឆ្នាំ២០១៣ ប្រជាពលរដ្ឋខ្មែរ ប្រគល់ សេចក្ដី ទុកចិត្ត ច្បាស់លាស់ គ្មានច្រឡំ គឺថា នាំ គ្នាបោះឆ្នោតឲគណបក្សសង្គ្រោះជាតិ តែបែរ ជា អ្នកដឹងនាំ នាំគ្នា ដើរ ចូលរដ្ឋសភា ជា អ្នកចាញ់ទៅវិញ។ សំរាប់ ការបោះឆ្នោតឆ្នាំ ២០១៨ ពួកគេ ប្តូរ ពាក្យស្លោក ថាជា «ដំណើរទៅរកការឈ្នះ»។ សួរថា បើខ្លួនជាអ្នកឈ្នះរួចទៅហើយ តើនាំគ្នា ដើរទៅរក ការឈ្នះអ្វីមួយទៀត ? តើឈ្នះ នៅឆ្នាំ ២០១៨ វាខុសគ្នា បែបណាពី ការឈ្នះ ២០១៣ ?

សកម្មភាព នៃ គណបក្សសង្គ្រោះជាតិ ក្នុង អាណត្តិទី៥ គឺមានសភាព អស្ចារ្យណាស់សំរាប់អ្នកម្ចាស់ឆ្នោត អាម៉ាស់មុខ ពី ការក្បត់ នៃឆន្ទៈរបស់ខ្លួន ពីសំណាក់អ្នកដឹកនាំគណបក្សសង្គ្រោះជាតិ គឺថា ពួក គេ នាំគ្នា ដូរ ឧត្តមគតិ ទាំងស្រុងខុសពីឆន្ទៈម្ចាស់ឆ្នោត ពី អ្នកប្រឆាំង ទៅជា បរាជ៏ន (subordonné) របស់ គណបក្ស កាន់អំណាចហើយ អ្វី ជា ការអស្ចារ្យ ដែលគ្មាន នរណា នឹកស្មាន ដល់បាន គឺ ការជប់លៀង ជា សាធារណៈ នៅ ក្នុង ភោជនីយដ្ឋាន ថ្លៃបំផុត នៅស្រុកខ្មែរ រវាង សម សង្ស៊ី នឹង ហ៊ុន សែន ចុះនាម នៅ ក្នុង វប្បធម៌សន្ទនា មាន លក្ខណៈ ជា សមាគមនយោបាយសម្ងាត់មួយទៀត ពី លើ សមាគមនយោបាយសម្ងាត់ រវាង គណបក្ស ជាសមាសភាព នៃគណ

បក្សសង្គ្រោះជាតិ។ តើ ទង្វើ បែបនេះ លោក សម រង្ស៊ី គាត់ ទុក ជា មរតកនយោបាយ របស់ សម្ដេច សីហនុ ដែល ខ្លួនគាត់ តែងតែ ទាមទារ ថាគាត់ជាទាយាទនយោបាយ ? បើជាការពិត មរតកនេះ គឺជាថ្នាំពុល សំរាប់ប្រជាជាតិខ្មែរ នោះឯង។

គណបក្ស សង្គ្រោះជាតិ អាច នឹង ឈ្នះឆ្នោត ម្ដងទៀត នៅឆ្នាំ ២០១៨ ដ្បិទ ប្រជាពលរដ្ឋ គាត់នឹង បោះឲ ដោយ គាត់ គ្មានជម្រើស ទោះបីមាន គណបក្សថ្មី ពីរទៀត គឺ គណបក្ស អំណាចខ្មែរ ដឹកនាំដោយ លោក សួន សេរីរដ្ឋា និង គណបក្ស សម្ព័ន្ធ ដើម្បីប្រជាធិបតេយ្យ ដឹកនាំ ដោយ លោក ម៉ម សូណង់ដូ ចូលរួម ប្រកួត តែ ជាជ័យជំនះចែកសម្លេង ជាមួយ គណបក្សទាំងពីរនេះ។ សភាព បែបនេះហើយ ដែលជា គ្រោះថ្នាក់ដល់ អ្នកជាប់ឆ្នោតទាំងបី នៅ ក្នុងបរិបទ នៃ នយោបាយ នៅស្រុកខ្មែរ ព្រោះដូចបានជំរាប រួចហើយ ថា គណបក្ស នយោបាយ មាននៅស្រុកខ្មែរ មិនសូវ មានគុណសម្បត្តិ ជា គណបក្សនយោបាយ នោះឡើយ ព្រោះ អ្នកដឹកនាំ ជា ថៅកែ នៃគណបក្ស ហើយ ទុក អត្ថប្រយោជន៍ខ្លួន មុន គណបក្ស។ ជួនកាល គណបក្សនោះ គ្មានទាំងឧត្តមគតិ នយោបាយ ពិតប្រាកដ ផង ដែរ នាំ ឲ អ្នកដឹកនាំ ធ្វើ ឧបាយបញ្ឆោតយ៉ាងងាយស្រួល បំផុត ដល់សមាជិក ដើម្បី រកប្រយោជន៍។ ដូច្នេះ គណបក្សបែបនេះ ក្លាយជាទំនិញ សំរាប់ អ្នកផ្ដាច់ការនិយម គេទិញ យកមក បំរើប្រយោជន៍គេ។ ត្រូវនាំគ្នាចាំមើល តើ នរណាខ្លះ ក្នុងចំណោម មេ គណបក្សចូលរួមបោះឆ្នោត អាចនឹង ក្បត់ម្ចាស់ឆ្នោត ចូលទៅធ្វើសហប្រតិបត្តិការណ៍ជាមួយគណបក្សកាន់ អំណាច នៅ ក្នុង អាណត្តិទី៦ ដើម្បី រកប្រយោជន៍។ ត្រូចដឹងថា ទោះបី គណបក្ស ប្រជាជន ចាញ់ ឆ្នោតពិត តែបក្សនេះ មាន ចំនួន អ្នកបោះឆ្នោត ឲ ខ្លួន ពិតប្រាកដ និង មាន មធ្យោបាយ ជា សម្ភារៈ សំរាប់ ទិញ អ្នកនយោបាយ ដែល គ្មាន ឧត្តមគតិជាតិ ពិប្រាកដ ដើម្បី បន្ត រស់នៅ ក្នុងឆាកនយោបាយ ហើយ ប្រើអំណាចរដ្ឋ ដើម្បី រក្សា អំណាចខ្លួន។ រូបភាពនេះ វាមាន តាំងតែ ពី អាណត្តិ ទី១ មកម្លេះ។ សួរថា តើមាន កត្តាណាខ្លះ ដែលអាច ឲខ្មែរមានជំនឿថា ស្ថានភាព ដែលធ្លាប់មាន ហើយ ស្ទើរទុក ជា ហ្លាក់ឋាន (situation régulière) ទៅហើយ វា នឹង អាច ឈប់កើត វិញបាន នៅក្នុង អាណត្តិ ទី៦ ? យើងឃើញថា នាដការ នយោបាយ សំខាន់ៗ ដែលខ្មែរយើង ស្គាល់ ចរិតគាត់ច្បាស់លាស់នៅតែ ជាអ្នកដឹកនាំដដែល។ សួរថាតើ លោក សួន សេរីរដ្ឋា លោក ម៉ម សូណង់ដូ គាត់ជា នាដការ ថ្មីឬ ? អ្វី ដែល អាច ទុកជា របស់ ថ្មី វា ស្រេចនៅលើ ទេសភាពនយោបាយ បើ គ្មាន ដូរ ទេសភាពចាស់ គឺ មិនអាច មាន អ្វី កើត ថ្មី នោះឡើយ ដូច្នេះ លោក សួន សេរីរដ្ឋា ម៉ម សូណង់ដូ ក្ដី គ្រាន់តែ ជា សេចក្ដី សង្ឃឹម ចាស់ យកមកបង្ហាញ ជាថ្មី នៅក្នុង ការបោះឆ្នោត តាម របៀបចាស់ ដដែល គឺ ការបោះឆ្នោតមួយ សំរាប់ តែការពារអំណាច លោក ហ៊ុន សែន តែប៉ុណ្ណោះ។

មួយជំហានម្ដងៗ របស់គណបក្ស សង្គ្រោះជាតិ គឺជាដំតដ្ឋមួយដំៗ យកមកផ្គុំគ្នាឲបានកើត ជា ទំនប់ ទប់ទឹក លទ្ធិប្រជាធិបតេយ្យ កុំឲ ហូរ លិច អំណាច ផ្ដាច់ការ នៅស្រុកខ្មែរ តែប៉ុណ្ណោះ។ មួយជំហាន ទៅមួយជំហាន គឺជា ការពង្រឹង អំណាចផ្ដាច់ការ

មួយដំណាក់ ទៅមួយដំណាក់ ដូច្នេះ ឆ្នាំ២០១៨ ជា ដំណាក់ថ្មី ដោយ យក ការបោះឆ្នោត គ្មានសេរី គ្មានយុត្តិធម៌ ជារបៀបចាស់ មក ធ្វើជា ចលករ រុញ លទ្ធិផ្តាច់ការ ឲដើរ ទៅមុខ ជានិច្ច។ តែស្រុកខ្មែរ មិន អាច យក លំអាន របស់ប្រទេស ភូមា មកអនុវត្តន៍បាននោះឡើយ ដែលជាវិធី មួយ ត្រូវ ការពេលវេលាយូរ ព្រោះ នៅស្រុកខ្មែរ មាន ហានិភ័យយួន ដែល យួន ត្រូវការពេលវេលារហ័ស សំរាប់ប្រយោជន៍ យៀកណាម ដែល គេមាន ជំហានគេ ច្បាស់លាស់ ដើរស្របនឹង មួយជំហានម្តងៗ របស់ គណបក្ស សង្គ្រោះជាតិ។ តែយើងដឹងថា ដើរ មួយជំហានគ្មានលំនឹង គឺជា ទឹកជំនន់ នៃជនជាតិយួន ហូរចូលមក បំពេញ ដីខ្មែរ ម្តងមួយខេត្តៗ។

បើ អ្នកនយោបាយខ្មែរ និង អ្នកដឹកនាំខ្មែរ មើល មិនឃើញ គ្រោះថ្នាក់នេះ ហើយ ប្រជាពលរដ្ឋខ្មែរ នៅតែ រង់ចាំ ព្រះបាទធម្មិក ចុះ មក ជួយខ្លួន គឺ ជា បាតប័ត្រ[1] អាចទុក ជា កម្ម របស់ ប្រជាជាតិខ្មែរ នោះឯង។

## សេចក្តីសន្និដ្ឋាន

ជ័យជំនះ ឆ្នាំ ២០១៨ ពិតជា មាន តែ ជាជ័យជំនះ នាំ ឲ ប្រជាពលរដ្ឋខ្មែរ នឹងអាចមានការខកចិត្ត ដដែល ដូចគ្នានឹង ឆ្នាំ ២០១៣។ តែ ប្រជាពលរដ្ឋ អាចមានលទ្ធភាពធ្វើមិនឲមាន ការខកចិត្តនេះ កើតឡើងវិញបាន គឺ ទាមទារ ឲ មាន កាបោះឆ្នោតមួយនៅក្រោម ការត្រួតពិនិត្យ នៃ អង្គការ សហប្រជាជាតិ តាម ការធ្វើបាតុកម្មអហឹង្ស ដែលជា សទ្ធិ របស់ខ្លួន ជា ប្រជាពលរដ្ឋ។ បើការទាមទារនេះ គ្មានចម្លើយ គឺ ត្រូវនាំគ្នាធ្វើពហិការ កុំ ចូលរួម បោះឆ្នោត ព្រោះវា គ្មានសេរី គ្មាន យុត្តិធម៌។ គុណសម្បត្តិរបស់ ប្រជាពលរដ្ឋល្អ គឺ ជា ប្រជាពលរដ្ឋ មាន ការចេះប្រមាណ មាន សេចក្តីក្លាហាន និង មាន ការប្រយ័ត្ន។ បើ ប្រជាពលរដ្ឋខ្មែរ មាន គុណសម្បត្តិ ទាំងបីយ៉ាងនេះ គឺ ពិតជា អាចឈ្នះ អំណាចផ្តាច់ការបាន និង បង្ខំ អ្នកនយោបាយ បោកប្រាស់ ឲឈប់កុហកខ្លួន។ សេចក្តីសង្ឃឹម គឺ មាន នៅ ក្នុង កម្លាំង ប្រជាពលរដ្ឋ ខ្លួនឯង គ្មានបុគ្គលណា ក្រុមណា អាចបង្កើត ឲមានបាន នោះឡើយ។ យើងឃើញ ថា ដោយសារ តែមានសង្ឃឹម ទៅលើ អ្នកនយោបាយបោកប្រាស់ នោះឯង ដែល នាំ ឲ ប្រជាជាតិខ្មែរ បាត់ពេលវេលា ដ៏ថ្លៃថ្លា ៥ ឆ្នាំ បន្ថែមទៀត ទុកអោយ ជនជាតិយួន ហូរ ចូល ស្រុក បន្ថែមទៀតដែរ។ ខ្មែរមិនមែន ជា ជាតិសាសន៍ ប្រកាន់ពូជសាសន៍ នោះឡើយ ដូច្នេះខ្មែរ មិនទុកយួនជា សត្រូវនឹងខ្លួន នោះទេ តែ ខ្មែរ ចាំបាច់ការពារ បូរណភាពទឹកដី នៃប្រជាជាតិខ្លួន ពីការហូរចូលឥតច្បាប់ទំលាប់ នៃ ជនជាតិយួន មកក្នុង ស្រុកខ្លួន។ បើ ខ្មែរយើងនាំគ្នាដេកចាំ ការបោះឆ្នោត គ្មានសេរី គ្មានយុត្តិធម៌ គឺ ជា ការរង់ចាំ សំរាប់

[1] បាតប័ត្រ = ការបោះបង់ចោលសទ្ធិរបស់ខ្លួនឯងឲទៅអ្នកដទៃ (Résignation)។

សម្លាប់ជាតិ ឯងតែប៉ុណ្ណោះ។ ខ្មែរ ត្រូវហ៊ាន ដើប តស៊ូ តាមសន្តិវិធី ការពារប្រយោជន៍ ជាតិខ្មែរ សំរាប់ ជីវិត ដ៏ប្រសើរ របស់ខ្លួន និង អនាគត របស់ ប្រជាជាតិខ្មែរ។ នេះ ជា មាគ៌ា តែ មួយ គត់ ដែល ខ្មែរយើង ត្រូវនាំគ្នា ដើរ ព្រោះជាផ្លូវដើរទៅរក សេចក្តី ថ្លៃថ្នូរ របស់ ប្រជាពលរដ្ឋខ្មែរ ដែល ជា សេចក្តីថ្លៃថ្នូរ របស់មនុស្សលោក ដែលមានច្បាប់ សទ្ធិមនុស្ស ក្នុងសាកលលោក ជា ច្បាប់សំរាប់ការពារ។

ឈ្នះឆ្នោត នៅឆ្នាំ ២០១៨ តែបើ ប្រជាពលរដ្ឋខ្មែរ មិនមែន ជាម្ចាស់អំណាច គឺ ជា ជ័យជំនះគ្មានការប្តូរ របប ដឹកនាំ បច្ចុប្បន្ន ដែល ជា របប ផ្តាច់ការ ធ្វើ អភិវឌ្ឍន៍ សំរាប់ បំរើ ចំណេញ ដល់ ពួក ឈ្មួញ ទុច្ចរិត សំរាប់ កសាង មហាយៀកណាម និង សំរាប់ ពួក អ្នកនយោបាយបោកប្រាស់ ចែកកៅអីគ្នាអង្គុយតែប៉ុណ្ណោះ។៚